ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៥ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹង និងលើកកម្ពស់ការសិក្សាវប្បធម៌-អរិយធម៌ខ្មែរ

ដើម្បីបណ្តុះ និងពង្រឹងស្មារតីស្នេហាជាតិឱ្យកាន់តែខ្លាំងក្លា ព្រមទាំងចូលរួមអភិរក្ស និងលើកកម្ពស់វប្បធម៌ជាតិខ្មែរឱ្យបានគង់វង្ស និងរីកចម្រើនថែមទៀត ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដូចខាងក្រោម៖

១- គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទាំងអស់ ត្រូវចាត់ចែងរៀបចំ និងរកឯកសារពាក់ព័ន្ធនឹងការពង្រីកចំណេះលើផ្នែកវប្បធម៌-អរិយធម៌ ដូចមានរាយចំណងជើងក្នុងឧបសម្ព័ន្ធខាងក្រោមដាក់នៅក្នុងបណ្ណាល័យសាលា ដើម្បីឆ្លើយតបនឹងការសិក្សារបស់សិស្ស។
២- រៀបចំយន្តការចូលអាន និងសិក្សាក្នុងបណ្ណាល័យ ដោយចែកវេន ឬរៀបកាលវិភាគឱ្យបានច្បាស់លាស់ និងបង្កលក្ខណៈងាយស្រួលក្នុងការអាន សិក្សា និងស្រាវជ្រាវ។
៣- ជំរុញសិស្សឱ្យចូលអាន សិក្សា និងស្រាវជ្រាវ លើឯកសារទាំងនេះ ដោយមានការដឹកនាំ និងសម្របសម្រួលសិក្សា ដោយគ្រូឈរថ្នាក់ ឬគ្រូឯកទេសភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងសិក្សាសង្គម ព្រមទាំងមានការផ្តល់សេវាយ៉ាងល្អ និងត្រឹមត្រូវពីបណ្ណារក្ស។
៤- ជំរុញសិស្សឱ្យចូលខ្ចី និងបំផុសឱ្យសិស្សរកជាវសៀវភៅទាំងនេះយកទៅអាននៅផ្ទះ ដោយគ្រូដាក់បញ្ហា ដូចជាសំណួរ ឬលំហាត់ និងធ្វើការត្រួតពិនិត្យ កែលម្អនាពេលបន្ទាប់។
៥- អង្គភាពពាក់ព័ន្ធ គណៈគ្រប់គ្រងសាលា និងអ្នកទទួលបន្ទុកបច្ចេកទេស ត្រូវជំរុញ តាមដាន និងវាយតម្លៃការអនុវត្តការសិក្សាខ្លឹមសារវប្បធម៌-អរិយធម៌ខ្មែរ ឱ្យបានហ្មត់ចត់ និងមានប្រសិទ្ធភាព។
៦- រៀបចំចេញវិញ្ញាសាប្រឡងប្រចាំខែ ប្រឡងឆមាស និងប្រឡងថ្នាក់ជាតិ ក្នុងមុខវិជ្ជាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ និងសិក្សាសង្គម។
៧- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាត្រូវរៀបចំគម្រោងថវិកាសម្រាប់ជាវ ឬថតចម្លង សម្រាប់ដាក់ក្នុងបណ្ណាល័យ ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សាសាធារណៈមួយចំនួន ដែលគ្មានលទ្ធភាពដើម្បីបម្រើឱ្យការសិក្សាទាន់ពេលវេលា និងមានប្រសិទ្ធភាព។
៨- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាត្រូវសហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍនានា ដោយកៀរគររកមូលនិធិ ដើម្បីទ្រទ្រង់ និងបម្រើឱ្យការសិក្សាវប្បធម៌-អរិយធម៌ខ្មែរឱ្យមានគុណភាព និងនិរន្តរភាព។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់ ចូលរួម សហការ ផ្សព្វផ្សាយ និងអនុវត្តប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត «ដើម្បីជ្រាបជាព័ត៌មាន»
- គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន «ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា